# បញ្ញាដកសិក្ខាបទ



១. ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ល្អណាស់ហើយឧបសេន ភិក្ខុមិនត្រូវបញ្ញត្តនូវសិក្ខាបទដែលតថាគត មិនទាន់បានបញ្ញត្តហើយ ម្យ៉ាងទៀតមិនត្រូវដកនូវសិក្ខាបទដែលតថាគតបញ្ញត្តហើយ ត្រូវប្រព្រឹត្តកាន់យកតាមសិក្ខាបទដែលតថាគតបានបញ្ញត្តទុកហើយ ឧបសេន តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ អ្នកប្រព្រឹត្តបិណ្ឌបាត នឹងប្រព្រឹត្តបង្សុកូលចូលទៅរកតថាគតតាមសប្បាយចុះ ។

*(វិនយបិដក មហាវិភង្គ និស្សគ្គិយកណ្ឌ កោសិយវគ្គ និសីទនសន្ថតសិក្ខាបទ បិដកលេខ ៣ ទំព័រ ១០៨)*

២. ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនបញ្ញត្តសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ មិនដកសិក្ខាបទ ដែលតថាគតបញ្ញត្តហើយ កាន់តាមប្រព្រឹត្ត តាមសិក្ខាបទដែលតថាគតបញ្ញត្តហើយយ៉ាងណា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តី សាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

*(សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ អបរិហានិយធម៌ បិដកលេខ ១៦ ទំព័រ ១៦៥)*

៣. ម្នាលអានន្ទ លុះអំណើះតតពីតថាគតទៅ បើសង្ឃមានប្រាថ្នានឹង ដកសិក្ខាបទ ចូរដកសិក្ខាបទ ដែលតូចនិងតូចដោយលំដាប់ចុះ ម្នាលអានន្ទ អំណើះតតពីតថាគតទៅ សង្ឃត្រូវដាក់ព្រហ្មទណ្ឌ ដល់ឆន្នភិក្ខុផងចុះ ។

(សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ តថាគតបច្ឆិមវាចា បិដកលេខ ១៦ ទំព័រ ៣២១)

៤. គ្រានោះឯង ព្រះមហាកស្សបមានអាយុ ក៏ប្រកាសសង្ឃថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយ របស់ពួកយើងក៏មានតាំងនៅក្នុងពួកគ្រហស្ថ សូម្បីពួកគ្រហស្ថទាំងឡាយ ក៏តែងដឹងថា អំពើនេះគួរដល់លោកទាំងឡាយ ជាសមណសក្យបុត្តិយ៍ អំពើនេះមិនគួរដល់លោកទាំងឡាយទេ ។ បើយើងទាំងឡាយនឹងដកនូវសិក្ខាបទតូច ៗ ដោយលំដាប់ចេញហើយ មុខជាជនទាំងឡាយជាអ្នកពោលតិះដៀលនឹងពោលថា សិក្ខាបទដែលព្រះសមណគោតម បញ្ញត្តហើយដល់សាវ័កទាំងឡាយ បានតែត្រឹមធូមកាលិក គឺកាលនៃផ្សែងភ្លើងគឺបរិនិព្វានប៉ុណ្ណោះ ព្រះសាស្តារបស់សាវ័កទាំងឡាយនេះ បិតនៅត្រឹមណា សាវ័កទាំងនេះ នាំគ្នាសិក្សាក្នុងសិក្ខាបទត្រឹមនោះ កាលណាបើព្រះសាស្តារបស់សាវ័កទាំងនេះបរិនិព្វានហើយ ឥឡូវនេះ សាវ័កទាំងនេះ ក៏លែងសិក្សាក្នុងសិក្ខាបទទាំងឡាយដែរ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីបញ្ញត្តថែមនូវសិក្ខាបទដែលព្រះជាគ្រូមិនបានបញ្ញត្តទេ កុំគប្បីដកចេញនូវសិក្ខាបទ ដែលព្រះជាគ្រូបញ្ញត្តមកហើយ ត្រូវសមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលព្រះជាគ្រូទ្រង់បញ្ញត្តហើយ ។ នេះជាញត្តិ ។ ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើងក៏មានតាំងនៅក្នុងពួកគ្រហស្ថ សូម្បីពួកគ្រហស្ថទាំងឡាយតែងដឹងថា អំពើនេះគួរដល់លោកទាំងឡាយជាសមណសក្យបុត្តិយ៍ អំពើនេះមិនគួរដល់លោកទាំងឡាយទេ ។ បើយើងទាំងឡាយនឹងដកនូវសិក្ខាបទតូច ៗ ដោយលំដាប់ចេញហើយ មុខជាជនទាំងឡាយ

ជាអ្នកពោលតិះដៀលនឹងពោលថា សិក្ខាបទដែលព្រះសមណគោតមបានបញ្ញត្តដល់ពួកសាវ័កបានត្រឹមតែធូមកាលិក គឺកាលនៃផ្សែងភ្លើងប៉ុណ្ណោះ ព្រះសាស្តារបស់សាវ័កទាំងនេះឋិតនៅត្រឹមណា សាវ័កទាំងនេះ ក៏នាំគ្នាសិក្សាក្នុងសិក្ខាបទត្រឹមនោះ កាលបើព្រះសាស្តារបស់សាវ័កទាំងនេះ បរិនិព្វានទៅហើយឥឡូវសាវ័កទាំងនេះ ក៏លែងសិក្សាក្នុងសិក្ខាបទទាំងឡាយដែរ ។ សង្ឃមិនបញ្ញត្តថែមនូវសិក្ខាបទដែលព្រះជាគ្រូមិនបានបញ្ញត្តទេ មិនដកចេញនូវសិក្ខាបទ ដែលព្រះជាគ្រូបានបញ្ញត្តហើយ សមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយដែលគួរដល់ពុទ្ធប្បញ្ញត្តិ ។ ការមិនបញ្ញត្តិថែមនូវសិក្ខាបទដែលព្រះអង្គមិនបានបញ្ញត្ត ការមិនដកចេញនូវសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្ត ការសមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលគួរដល់ពុទ្ធប្បញ្ញត្តិ គាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីពោលឡើង ។ សង្ឃមិនបានបញ្ញត្តថែមនូវសិក្ខាបទដែលព្រះអង្គមិនបានបញ្ញត្ត មិនដកចេញនូវសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្ត សមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលគួរដល់ពុទ្ធប្បញ្ញត្តិ ។ ការមិនបញ្ញត្តិនឹងការមិនដកនូវសិក្ខាបទនេះគាប់ចិត្តដល់សង្ឃព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្តីនេះ ដោយការស្ងៀមយ៉ាងនេះ ។

(វិនយបិដក ចូឡវគ្គ បញ្ចសតិកក្ខន្ធកៈ បិដកលេខ ១១ ទំព័រ ៣៦៧)

ដោយស.ជ.វ.ថ.